# ពិធីប្រគល់ទទួលឧបករណ៍មន្ទីរពិសោធន៍របស់ប្រទេសអូស្ត្រាលី
# មកអគ្គនាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម

ពិធីប្រគល់ទទួល ឧបករណ៍ មន្ទីរពិសោធន៍របស់ប្រទេស អូស្ត្រាលី មកអគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ត្រូវបានប្រារព្ធ ធ្វើឡើងកាលពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ នៅគ្រឹះស្ថានរបស់លោកជំទាវ ឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលីប្រចាំនៅកម្ពុជា ស្ថិតនៅសង្កាត់ ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ រវាង **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋ មន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកជំទាវ **Margaret Adamson** ឯកអគ្គរដ្ឋទូត នៃប្រទេសអូស្ត្រាលី ប្រចាំនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមថ្នាក់ដឹកនាំ ក្រសួងពាណិជ្ជកម្ម និងមន្ត្រីនៃស្ថានទូតអូស្ត្រាលីមួយចំនួនផងដែរ ។

ឧបករណ៍ដែលទទួលក្រោមជំនួយរបស់ប្រទេសអូស្ត្រាលី គឺសំរាប់កម្មវិធីកសាងសមត្ថភាព វិស័យអនាម័យ និងភូតគាមអនាម័យ រួមមាន ៖ ប្រព័ន្ធមីក្រូស្កុប និងប្រដាប់ប្រដាអុបទិកមួយចំនួន ដែលមានទិសដៅប្រើប្រាស់សំរាប់ស្រាវជ្រាវ និងកំណត់អត្តសញ្ញាណ ពពួកមីក្រូសរីរាង្គដូចជា ៖ បាក់តេរី ផ្សិត និងប៉ារ៉ាស៊ីត ក្នុងផលិតផលម្ហូបអាហារ និងពពួកសត្វល្អិតចង្រៃនៅក្នុងផលិតផលកសិកម្ម ដែលមានសារៈប្រយោជន៍ យ៉ាងសំខានសំរាប់ការនាំចេញផលិតផលកសិកម្មរបស់កម្ពុជាអោយសមស្របតាមស្តង់ដារតំរូវ (SPS) លើទីផ្សារអន្តរជាតិ ។

ថ្លែងក្នុងឱកាសនោះ លោកជំទាវឯកអគ្គរដ្ឋទូតបានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាបថា ៖ ការប្រគល់ឧបករណ៍ទាំងនេះ គឺធ្វើឡើងដោយ ឆ្លើយតបទៅនឹងសំណើរបស់ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក្នុងឱកាសដែលឯកឧត្តមបាន ជួបអតីតឯកឧត្តមរដ្ឋ មន្ត្រីពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី នៅសម័យប្រជុំអាស៊ានលើកមុន ហើយដែល ឯកឧត្តមរដ្ឋមន្ត្រី ពាណិជ្ជកម្មអូស្ត្រាលី បានសន្យាថានឹងជួយផ្តល់ ឧបករណ៍ខាងលើមកកម្ពុជា ។

ថ្លែងក្នុងឱកាសនោះផងដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវអំណរគុណ ចំពោះឯកឧត្តមរដ្ឋមន្ត្រីពាណិជ្ជកម្មអូស្ត្រាលី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈលោកជំទាវឯកអគ្គរដ្ឋទូត ដែលបានផ្តល់ឧបករណ៍ ទាំងនេះមកកម្ពុជា ហើយការផ្តល់នេះគឺចំពេលដែលប្រទេសជាសមាជិកនៃអង្គការ ពាណិជ្ជកម្មពិភពលោក ដូចជាប្រទេសកម្ពុជាកំពុងប្រឈមនឹងបញ្ហាអនាម័យ និងភូតគាមអនាម័យនេះ ដែលហៅថា របាំងមិនមែនពន្ធគយ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានគូសបញ្ជាក់ទៀតថា ការផ្តល់ឧបករណ៍មន្ទីរពិសោធន៍ខាងលើរបស់ប្រទេស អូស្ត្រាលីនេះ គឺធ្វើឡើង ស្របទៅនឹងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយកដ្ឋានរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងចាប់ផ្តើមដាក់អោយអនុវត្តនូវ គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ជាពិសេស នឹងធ្វើឱ្យកម្ពុជាមានលទ្ធភាពនាំចេញផលិតផលកសិកម្មរបស់ខ្លួនច្រើនថែមទៀត ទៅកាន់ទីផ្សារអន្តរជាតិ ដោយបំពេញបានតាមលក្ខខណ្ឌតំរូវរបស់ប្រទេសអ្នកនាំចូល ។